រឿង

# ដង្កូវ និង ក្អែក



# ដង្កូវ និង ក្អែក

រៀបរៀងដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)

គូររូបដោយលោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)

បោះពុម្ពឆ្នាំ២០១១

សៀវភៅរូបភាពសម្រាប់កុមារ លេខ ២

# រឿង ដង្កូវ និងក្អែក

**ដកស្រង់ចេញពីសៀវភៅប្រជុំរឿងព្រេងខ្មែរ ភាគ ១**

រៀបរៀងដោយ បណ្ណាល័យអង្គការសន្តិស្ម័គ្រចិត្ត *(SVA)*
គូររូបភាពដោយ គឹម សុគន្ធ
ត្រួតពិនិត្យដោយ អង្គការសន្តិស្ម័គ្រចិត្ត *(SVA)*



បោះពុម្ពលើកទី ៣ ចំនួន ៣ ០០០ ច្បាប់
©រក្សាសិទ្ធិដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)
បោះពុម្ពនៅរោងពុម្ព Digital Advertising
ភ្នំពេញ ខែ ឧសភា ឆ្នាំ ២០១១



ថ្ងៃមួយមានសត្វដង្កូវមួយ កំពុងស៊ីស្លឹកឈើ ។ មានសត្វក្អែកមួយហើររកចំណីទៅប្រទះនឹងដង្កូវនោះ ។ ដង្កូវឃើញក្អែកភ័យណាស់ ព្រោះនឹកថា "ក្អែកនេះនឹងស៊ីអញឥឡូវនេះហើយ" ។ ដង្កូវក៏សួរក្អែកថា "មករកអ្វី?" ក្អែកឆ្លើយ "អញមកស៊ីដង្កូវឯង" ។ ដង្កូវថា "បើឯងចង់ស៊ីអញ លុះណាតែឯងឆ្លើយប្រស្នាអញបាន បើឆ្លើយមិនបានទេ ស៊ីអញមិនបានឡើយ" ។ ក្អែកសួរប្រស្នានោះដូចម្ដេច? សួរមកចុះ! ។



ជង្ហុកសួរទៅក្អែក ដូចតទៅ ៖

១. ដូចម្តេចដែលហៅថា ផ្អែមជាងគេបំផុត ?

២. ដូចម្តេចដែលហៅថា ជូរចត់ជាងគេបំផុត ?

៣. ដូចម្តេចដែលហៅថា ស្អុយជាងគេបំផុត ?

៤. ដូចម្តេចដែលហៅថា ក្រអូបជាងគេបំផុត ?



កាលបើក្អែកឮប្រស្នានេះ វាត្រេកអរណាស់ វាស្រែកហោកញ្ច្រៀវដោយគិតថាប្រស្នានេះងាយស្រួល ហើយវានឹងបានស៊ីជង្គូរនេះជាមិនខាន ។ វាបានឆ្លើយយ៉ាងក្បោះក្បាយថា ៖

១. ដែលហៅថា ផ្អែមជាងគេបំផុត គឺ ស្ករ និងទឹកឃ្មុំ ។

២. ដែលហៅថា ជូរចត់ជាងគេបំផុត គឺ ម្ទូរក្រូចឆ្មារ អម្ពិល ម្ទូរសណ្តាន់ ម្ទូរក្រសាំង ម្ទូរទឹកខ្មេះ ។

៣. ដែលហៅថា ស្អុយជាងគេនោះ គឺ អាចម៍ និងគម្រង់ខ្មោចសត្វទាំងពួង ។

៤. ដែលហៅថា ក្រអូបជាងគេបំផុតនោះ គឺ ផ្ការំដួល ផ្កាម្លិះ និងទឹកអប់ ។



ដង្កូវឮហើយ និយាយថា "ក្អែកឆ្លើយប្រស្នានេះមិនត្រូវទេ" ។ ក្អែកក៏ធ្វើមុខស្រងូតនិយាយទៅដង្កូវវិញថា "យី! បើឯងថាមិនត្រូវសុំឯងប្រាប់ប្រស្នានោះឱ្យបានដឹងផង" ។

ដង្កូវប្រាប់ទៅក្អែកវិញថា " ប្រាប់បានតែឯងកុំស៊ីអញទើបអញប្រាប់" ។ ក្អែកថា "ឱ្យតែប្រាប់ចុះ អញមិនស៊ីដង្កូវឯងទេ" ។



លុះបានព្រមព្រៀងគ្នាដូច្នោះហើយ ដង្កូវក៏ឆ្លើយប្រស្នាប្រាប់ក្អែកដូចតទៅ ៖

១. ដែលហៅថា ផ្អែមជាទីបំផុតនោះ មិនមែនផ្អែមស្ករ ទឹកឃ្មុំទេ គឺផ្អែមពាក្យសំដី ដែលនិយាយទៅមករកគ្នា ដោយពាក្យពីរោះស្មោះត្រង់រកគ្នា ។

២. ដែលហៅថា ជូរចត់ជាទីបំផុតនោះ មិនមែនជូរចត់អម្ពិលសណ្ដាន់ ក្រូចឆ្មារ ទឹកខ្មេះនោះទេ គឺពាក្យផរុសវាទ ឃោរឃៅឥតគួរឥតសម ពេលនិយាយទៅកាន់គ្នាទៅវិញទៅមកនេះ ហៅថា "ជូរចត់លើសជូរចត់អ្វីទាំងពួង" ។

៣. ដែលហៅថា ស្អុយជាងគេនោះ មិនមែនស្អុយអាចម៍ ឬស្អុយគម្រង់នោះទេ គឺស្អុយកេរ្តិ៍ ស្អុយឈ្មោះដែលប្រព្រឹត្តអាក្រក់ក្នុងលោកនេះហើយ ហៅថា "ស្អុយច្រាស់ខ្យល់" ។

៤. ដែលហៅថា ក្រអូបនោះ គឺមិនមែនក្រអូបក្លិនផ្កា ឬទឹកអប់នោះទេ គឺក្រអូបកេរ្តិ៍ឈ្មោះដែលប្រតិបត្តិល្អ នេះហើយហៅថា "ក្រអូបជាងគ្រឿងក្រអូបទាំងពួង" ។

ក្អែកបានស្ដាប់ប្រស្នាទាំងនេះហើយ ក៏ឈប់ស៊ីដង្កូវទៅ ៕

## "តូចមែនពិត ដូចពេជ្រពណ្ណរាយ"

ចប់



អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association
*Move forward, hand in hand.*